**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ០២១ សសរ/គ.ជ.វ.វ

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០៧

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងមន្ត្រីអនុម័ត ពិនិត្យបញ្ជាក់ និងមន្ត្រីស្នើសុំទូទាត់របស់ក្រុមគាំទ្រកម្មវិធី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន
## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៧/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ១៦/អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសំរេចលេខ ០៩ សសរ/គ.ជ.វ.វ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការបង្កើតក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ)
- បានឃើញឯកសារគំរោងគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ ដែលបានចុះហត្ថលេខានាថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៧
- ផ្អែកលើលក្ខណៈចាំបាច់ការងារ

# សម្រេច

**ប្រការ ១.-**

តែងតាំងមន្ត្រីអនុម័តលើការចំណាយ សំរាប់គំរោង "ការគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ" (PSDD) គំរោង"ការវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន" (RILG) គំរោង"ការកាត់បន្ថយភាពក្រីក្រនៅជនបទខេត្តព្រៃវែងនិងស្វាយរៀង (RPRP) និងគំរោង" ការគ្រប់គ្រងធនធានធម្មជាតិនិងជីវភាពរស់នៅរបស់ប្រជាជន" (NRML)ដូចខាងក្រោម :

១- ឯកឧត្តម **ឈឿង យ៉ាណារ៉ា** ប្រធានក្រុមគាំទ្រកម្មវិធី ជាមន្ត្រីអនុម័តពេញសិទ្ធិ

២- ឯកឧត្តម **ខ៊ាន់ ចំរើន** អនុប្រធានក្រុមគាំទ្រកម្មវិធី ជាមន្ត្រីអនុម័តស្តីទី

**ប្រការ ២.-**

តែងតាំងមន្ត្រីពិនិត្យបញ្ជាក់ សំរាប់គំរោង "ការគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហ-មជ្ឈការ" (PSDD) គំរោង " ការវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន" (RILG) គំរោង"ការកាត់បន្ថយភាពក្រីក្រនៅជនបទខេត្តព្រៃវែងនិងស្វាយរៀង (RPRP) និងគំរោង" ការគ្រប់គ្រងធនធានធម្មជាតិនិងជីវភាពរស់នៅរបស់ប្រជាជន" (NRML)ដូចខាងក្រោម :

- ឯកឧត្តម **លេខ វី** អនុប្រធានក្រុមគាំទ្រកម្មវិធី ជាមន្ត្រីពិនិត្យបញ្ជាក់ពេញសិទ្ធិ
- លោក **គៀង សត្ថាវុធ** ជំនួយការ នាយកក្រុមគាំទ្រកម្មវិធី ជាមន្ត្រីពិនិត្យបញ្ជាក់ស្តីទី

**ប្រការ ៣.-**

តែងតាំងមន្ត្រីស្នើសុំទូទាត់ចំណាយ សំរាប់គំរោង"ការគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហ-មជ្ឈការ" (PSDD) គំរោង " ការវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន" (RILG) គំរោង"ការកាត់បន្ថយភាពក្រីក្រនៅជនបទខេត្តព្រៃវែងនិងស្វាយរៀង (RPRP) និងគំរោង" ការគ្រប់គ្រងធនធានធម្មជាតិនិងជីវភាពរស់នៅរបស់ប្រជាជន" (NRML) ដូចខាងក្រោម :

- លោក **ឡាយ ណាវុធ** ប្រធានផ្នែកហិរញ្ញវត្ថុក្រុមគាំទ្រកម្មវិធី ជាមន្ត្រីស្នើសុំទូទាត់ចំណាយពេញសិទ្ធិ
- លោក **ម៉ុង សេរី** មន្ត្រីផ្នែកហិរញ្ញវត្ថុក្រុមគាំទ្រកម្មវិធី ជាមន្ត្រីស្នើសុំទូទាត់ចំណាយស្តីទី

**ប្រការ ៤.-**

តែងតាំងមន្ត្រីស្នើសុំលទ្ធកម្ម រៀបចំលិខិតបញ្ជាទិញនិងកិច្ចសន្យា សំរាប់គំរោង"ការគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ" (PSDD) គំរោង" ការវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន" (RILG) គំរោង "ការកាត់បន្ថយភាពក្រីក្រនៅជនបទខេត្តព្រៃវែងនិងស្វាយរៀង (RPRP) និងគំរោង "ការគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាជន" (NRML)ដូចខាងក្រោម :

- លោក **យិន ម៉ាលីណា** ប្រធានផ្នែករដ្ឋបាលក្រុមគាំទ្រកម្មវិធី ជាមន្ត្រីស្នើសុំធ្វើលទ្ធកម្មពេញសិទ្ធិ
- លោក **ស៊ុន ស៊ីដេត** មន្ត្រីលទ្ធកម្មនៃក្រុមគាំទ្រកម្មវិធី ជាមន្ត្រីស្នើសុំធ្វើលទ្ធកម្មស្តីទី

**ប្រការ ៥.-**

ក្រសួង និងស្ថាប័នជាសមាជិក (គ.ជ.វ.វ) អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះ ក្រសួងមហាផ្ទៃ ប្រធាន និងអនុប្រធានក្រុមគាំទ្រកម្មវិធី ប្រធានផ្នែកទាំង ៤ នៃក្រុមគាំទ្រកម្មវិធី ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្ដីសម្រេចនេះ ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។ សេចក្ដីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃ០១ ខែកុម្ភៈ ឆ្នាំ២០០៧ តទៅ ។

**ប្រធាន គ.ជ.វ.វ**

**ស ខេង**

**កន្លែងទទួល :**

- ក្រសួងសមាជិក គ.ជ.វ.វ
- គណៈកម្មាធិការប្រតិបត្តិគ្រប់ខេត្ត ក្រុង
- ដៃគូអភិវឌ្ឍន៍ UNDP DFID SIDA
- គម្រោង PSDD
  (ដើម្បីជូនជ្រាប)
- សាមីខ្លួន
  (ដើម្បីអនុវត្ត)
- ឯកសារ